**សាររួមពី**

**លោក បាន គី-មូន (Ban Ki-Moon) អគ្គលេខាធិការអង្គការសហប្រជាជាតិ**

**អៀរីណា បូកូវ៉ា(Irina Bokova) អគ្គនាយកនៃអង្គការយូណេស្កូ (UNESCO) និង**

**ហ្សេដ រ៉ាអាដ អាល ហ៊ូសសេន (Zeid Ra'ad Al Hussein) ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

**នៅក្នុងឱកាសទិវាសេរីភាពសារព័ត៌មានពិភពលោក**

**ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៥**

សូមឲ្យសារព័ត៌មានចម្រើនលូតលាស់!

នេះគឺជាប្រធានបទនៃទិវាសេរីភាពសារព័ត៌មានពិភពលោក នៅឆ្នាំនេះ។

ឆ្នាំ២០១៥ នេះ រដ្ឋទាំងឡាយ បាន និងកំពុងពន្លឿនកិច្ចការរបស់ខ្លួន ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងបង្កើតឲ្យមានរូបរាងនូវរបៀបវារៈអភិវឌ្ឍជាសកលថ្មីមួយប្រកបដោយចីរភាព។ សេរីភាពក្នុងការសម្តែងមតិ និងសេរីភាពសារព័ត៌មាន គឺមានសារៈសំខាន់ក្នុងការសម្រេចបានជោគជ័យនៅគ្រប់កម្រិត។

សម្រាប់សន្តិភាពស្ថិតស្ថេរយូរអង្វែង និងការអភិវឌ្ឍប្រកបដោយចីរភាពនោះ គឺចាំបាច់ត្រូវតែមានការគោរពសិទ្ធិមនុស្ស។ បុគ្គលគ្រប់រូប ត្រូវតែមានសេរីភាពក្នុងការស្វែងរក ទទួល និងចែករំលែកចំណេះដឹង និងព័ត៌មាននៅលើគ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ មិនថាតាមអនឡាញ និងតាមអហ្វឡាញឡើយ។ សារព័ត៌មានដែលមានគុណភាព អាចឲ្យប្រជាពលរដ្ឋធ្វើការសម្រេចចិត្តបន្ទាប់ពីទទួលបានព័ត៌មានគ្រប់គ្រាន់ អំពីការអភិវឌ្ឍសង្គមរបស់ខ្លួន។ សារព័ត៌មានក៏អាចធ្វើការដើម្បីលាតត្រដាងអំពើអយុត្តិធម៌ អំពើពុករលួយ និងការរំលោភអំណាចផងដែរ។

សម្រាប់គោលដៅនេះ សារព័ត៌មានត្រូវតែអាចចម្រើនលូតលាស់ក្នុងបរិយាកាសមួយអំណោយផលដែលសារព័ត៌មានអាចធ្វើការដោយឯករាជ្យ និងដោយគ្មានការជ្រៀតជ្រែកហួសហេតុ និងក្នុងលក្ខខណ្ឌនៃសុវត្ថិភាព។ បច្ចុប្បន្ននេះ ពិភពលោកបានធ្វើជាសាក្សីនូវការវាយប្រហារគួរឲ្យរន្ធត់ប្រឆាំងនឹងអ្នកសារព័ត៌មានដែលយ៉ាងហោចណាស់ក៏មានអ្នកសារព័ត៌មានម្នាក់ដែរ ត្រូវបានគេសម្លាប់ជារៀងរាល់សប្តាហ៍ នៅតំបន់មានជម្លោះ និងតំបន់គ្មានជម្លោះ។ យើងត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេរដងថែមទៀត ដើម្បីពង្រឹងសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ចប់និទណ្ឌភាព ហើយនេះគឺជាគោលដៅនៃផែនការសកម្មភាពរបស់ អ.ស.ប ស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព ដែលអង្គការយូណេស្កូ ជាអ្នកនាំមុខគេ និងដោយមានការគាំទ្រពីស្ថាប័នដទៃផ្សេងទៀត របស់ អ.ស.ប ។

យើងត្រូវការរាល់សំឡេងទាំងអស់ សម្តែងចេញឲ្យឮសូរខ្លាំងៗ ហើយសំឡេងទាំងនោះត្រូវបានគេយកចិត្តទុកដាក់ស្តាប់ និងដោះស្រាយ - ជាពិសេសសំឡេងរបស់ស្ត្រី។ ម្ភៃឆ្នាំបន្ទាប់ពីសេចក្តីប្រកាស និងវេទិកាសកម្មភាពក្រុងប៉េកាំង ស្ត្រីនៅតែមានភាពជាតំណាងមិនទាន់គ្រប់គ្រាន់នៅទូទាំងប្រព័ន្ធផ្សព្វផ្សាយ មិនត្រឹមតែនៅកម្រិតធ្វើសេចក្តីសម្រេចចិត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងការផ្សព្វផ្សាយព័ត៌មានផងដែរ។ យើងមិនអាចទុកឲ្យបញ្ហានេះកើតមានតទៅទៀតឡើយ។ បុរស និងស្ត្រី ត្រូវតែចូលរួមដោយស្មើភាពគ្នាក្នុងការបង្កើត និងការចែករំលែកព័ត៌មាន។

សេរីភាពក្នុងការសម្តែងមតិ និងសេរីភាពសារព័ត៌មាន មិនមែនជាគុណលក្ខណៈប្រណីត ដែលអាចរង់ចាំរហូតទាល់តែសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាពឡើយ - វាគឺជាកម្លាំងជម្រុញឲ្យទទួលបានសិទ្ធិ មនុស្សទាំងអស់ ដូច្នេះហើយ វាសំខាន់ចំពោះអភិបាលកិច្ចល្អ និងនីតិរដ្ឋ។

នេះជាសាររបស់យើងនៅថ្ងៃនេះ សូមឲ្យសារព័ត៌មានចម្រើនលូតលាស់!

បាន គី-មូន អៀរីណា បូកូវ៉ា ហ្សេដ រ៉ាអាដ អាល ហ៊ូសសេ